KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

Department of Information


# PRESS RELEASE

At the invitation of His Excellency **PRAK Sokhonn**, Deputy Prime Minister, Minister of Foreign Affairs and International Cooperation of the Kingdom of Cambodia, His Excellency **Dr. Vivian Balakrishnan**, Minister of Foreign Affairs of the Republic of Singapore, will lead a delegation to pay an official visit to the Kingdom of Cambodia and to attend the ASEAN Foreign Ministers' Retreat (AMM Retreat) from 15 to 17 February 2022.

During the visit, His Excellency **Dr. Vivian Balakrishnan** will pay a courtesy call on **Samdech Akka Moha Sena Padei Techo HUN SEN**, Prime Minister of the Kingdom of Cambodia, and will have an official talks with His Excellency Deputy Prime Minister **PRAK Sokhonn** to disuss on bilateral relations and cooperation, including economic, trade, tourism, education, health, as well as regional and international issues of common interest and concern. His Excellency Foreign Minister of Singapore is expected to have separate meetings with His Excellency **Dr. AUN Pornmoniroth**, Deputy Prime Minister, Minister of Economy and Finance, His Excellency **SAY Samal**, Minister of Environment, and His Excellency **HUN Many**, Chairman of the Commission on Education, Youths, Sports, Religious Affairs, Culture and Tourism of the National Assembly of Cambodia.

The official visit of His Excellency **Dr. Vivian Balakrishnan** to Cambodia will further broaden and deepen close relations and cooperation between Cambodia and Singapore for the mutual benefit of the two nations.

Phnom Penh, 13 February 2022


Address : N° 3, **Samdech HUN Sen** Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
**នាយកដ្ឋានព័ត៌មាន**

## សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្ណាន់ រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសឹង្ហបុរី នឹងដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ និងចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន (ASEAN Foreign Ministers' Retreat) នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី១៥ ដល់ទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ។

ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្ណាន់ នឹងអញ្ជើញចូលជួបសម្តែងការគួរសមចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមានជំនួបពិភាក្សាផ្លូវការជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ដើម្បីពិភាក្សាអំពីកិច្ចសហ-ប្រតិបត្តិការទ្វេភាគី រួមមានវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ អប់រំ និងសុខាភិបាល ព្រមទាំងបញ្ហាតំបន់ និងអន្តរជាតិ ដែលជាចំណាប់អារម្មណ៍ និងក្តីបារម្ភរួម ។ ឯកឧត្តមរដ្ឋមន្ត្រីការបរទេសសឹង្ហបុរី ក៏នឹងមានជំនួបដាច់ដោយឡែកពីគ្នាជាមួយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រី ក្រសួងបរិស្ថាន និងឯកឧត្តម ហ៊ុន ម៉ានី ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភាកម្ពុជា ផងដែរ។

ដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្ណាន់ មកកាន់កម្ពុជា នឹងពង្រឹង និងធ្វើឱ្យស៊ីជម្រៅបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងកម្ពុជា និងសិង្ហបុរី ដើម្បីផលប្រយោជន៍រួមរបស់ប្រទេសទាំងពីរ៕

ថ្ងៃអាទិត្យ ១២កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២២

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh